# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ វត្តខ្មែរកាណាដា អំពីសកម្មភាពរាជរដ្ឋាភិបាលខ្មែរ ក្នុងដំណោះស្រាយព្រំដែនខ្មែរជាមួយប្រទេសជិតខាង

**Website: www.hoksavann.org**

ថ្ងៃទី១៧ កញ្ញា ២០០៤

ក្នុងបញ្ហាបូរណភាពទឹកដីនៃប្រទេសកម្ពុជា ត្រូវបានប្រជាពលរដ្ឋខ្មែរទាំងក្នុងនិងក្រៅប្រទេស មានការព្រួយបារម្ភយ៉ាងខ្លាំង ក្រែងទឹកដីរបស់ខ្លួនបាត់បង់តទៅទៀត ។ ជាមួយការព្រួយបារម្ភនោះ ប្រជាពលរដ្ឋបានធ្វើសកម្មភាពគ្រប់បែបយ៉ាង មានការធ្វើបាតុកម្ម ការធ្វើសេចក្តីថ្លែងការណ៍ប្រឆាំងនឹងប្រទេសជិតខាង មានប្រទេសវៀតណាមជាដើម ដែលបានរំកិលព្រំដែន ចូលមកក្នុងទឹកដីនៃប្រទេសកម្ពុជា ។ ប៉ុន្តែរាល់ការធ្វើបាតុកម្មការធ្វើសេចក្តីថ្លែងការណ៍ទាំងនោះ ពុំបានទទួលការស្វាគមន៍ពីរាជរដ្ឋាភិបាលខ្មែរឡើយ ។ ផ្ទុយទៅវិញ អាជ្ញាធរខ្មែរពុំអនុញ្ញាតច្បាប់ធ្វើបាតុកម្មប្រឆាំងនឹងវៀតណាមឡើយ ថែមទាំងបានបង្ក្រាបចលនានិស្សិតដែលហ៊ានធ្វើបាតុកម្ម ប្រឆាំងនឹងការឈ្លានពានទឹកដីរបស់វៀតណាម ដោយអំពើហិង្សាទៀតផង ។

នៅពេលថ្មីៗនេះ មានរបាយការណ៍មួយរបស់អង្គការការពារព្រំដែនកម្ពុជា ជាអង្គការឯកជនមួយនៅភ្នំពេញថា អាជ្ញាធរវៀតណាមទន្រ្ទានចូលដីត្រង់តំបន់-ស ដែលជាតំបន់ប្រទាញប្រទង់គ្នា ព្រមទាំងចូលមកភ្ជួរលើដីស្រែរបស់កសិករខ្មែរថែមទៀត នៅភូមិដូង ភូមិទូល ស្រុករមាសហែក ខេត្តស្វាយរៀង ។ តាមអង្គការនេះនិយាយថា វៀតណាមបានចូលមករំលោភលើដីខ្មែរប្រវែងពី៣០០ម៉ែត្រទៅ៥០០ម៉ែត្រ ។ របាយការណ៍នេះបានត្រូវប្រធានគណៈកម្មាធិការព្រំដែនកម្ពុជារបស់រដ្ឋាភិបាលមានប្រតិកម្មថា ជារឿងមិនពិត ។ ការបដិសេធភ្លាមៗថាពុំពិតនេះ ដោយខ្លួនពុំបានចុះទៅអង្កេតពិនិត្យឲ្យបានច្បាស់លាស់ តាមរបាយការណ៍នេះទេ គេជឿលើពាក្យអភិបាលខេត្តស្វាយរៀងតាមទូរស័ព្ទ ។ តើអាចដឹងការពិតឬទេ បើប្រធានគណៈកម្មាធិការព្រំដែនកម្ពុជា ទាំងអភិបាលខេត្តនៅតែក្នុងការិយាល័យ ។ មួយទៀត រឿងដែលនាំឲ្យប្រជាពលរដ្ឋពិចារណានោះ គឺវៀតណាមទន្រ្ទានដីខ្មែរពិតឬពុំពិតនេះ គឺជាភារកិច្ចរបស់អាជ្ញាធរវៀតណាមដែលត្រូវឆ្លើយ ដើម្បីការពារផលប្រយោជន៍របស់គេ ។ ប៉ុន្តែផ្ទុយទៅវិញ បែរជារដ្ឋាភិបាលខ្មែរដែលត្រូវការពារទឹកដីរបស់ខ្លួន ទៅជាឆ្លើយជំនួសអាជ្ញាធរវៀតណាមទៅវិញ ។ ដូច្នេះប្រធានគណៈកម្មាធិការព្រំដែនកម្ពុជាជាតំណាងឲ្យខ្មែរឬតំណាងឲ្យវៀតណាម ឬខ្លួនជាខ្មែរប៉ុន្តែបំរើឲ្យវៀតណាម នេះជាចម្ងល់របស់ប្រជាពលរដ្ឋខ្មែរទៅលើសកម្មភាពរបស់ប្រធានគណៈកម្មាធិការនេះ។ ព្រះមហាក្សត្រខ្មែរធ្លាប់បានមានព្រះរាជឱង្ការមិនទទួលស្គាល់គណៈកម្មាធិការព្រំដែនរបស់រដ្ឋាភិបាលទេ ព្រមទាំងមិនជឿសំដីរបស់ប្រធានគណៈកម្មាធិការនេះ ដែលអួតអាងថាការយកសន្ធិសញ្ញាអំឡុងឆ្នាំ៨០មកធ្វើជាមូលដ្ឋានក្នុងដំណោះស្រាយនាំឲ្យខ្មែរចំណេញដី ។ ប្រធានគណៈកម្មាធិការនេះ ថែមទាំងបានចោទប្រជាពលរដ្ឋរបស់ខ្លួនថា មានពេលខ្លះប្រជាពលរដ្ឋខ្មែរបានចូលទៅរំលោភលើដីវៀតណាមផង ។ រឹតតែសង្ស័យទៅទៀត ប្រជាពលរដ្ឋនិងប៉ូលិសខ្មែរដែលការពារព្រំដែន ពុំហ៊ានរាយការណ៍ដល់អ្នកយកពត៌មានទេ បើប៉ូលិសព្រំដែនណាហ៊ានរាយការណ៍ប្រាប់ការពិតដល់អ្នកយកពត៌មានថា វៀតណាមបានរំកិលព្រំដែន ប៉ូលិសនោះនឹងផ្លាស់ចេញពីទីនោះភ្លាម ។ បើពត៌មាននេះជាការពិតមែន តើអាជ្ញាធរខ្មែរបំរើផលប្រយោជន៍ខ្មែរ ឬឲ្យវៀតណាម ។ ថែមពីលើនេះទៀត មានពាក្យរបស់អាជ្ញាធរកំពូលខ្មែរម្នាក់ពោលថា បើខ្មែរណាហ៊ានទៅដេញវៀតណាមដែលរំលោភដីខ្មែរ អ្នកធំនោះនឹងធ្វើក្តារមឈូសចាំ ។ នេះជាពាក្យប្រមាថមើលងាយប្រជាពលរដ្ឋរបស់ខ្លួន ដែលខំការពារទឹកដីកុំឲ្យវៀតណាមរំលោភយក គឺជាការបង្អាក់ដំណើរនិងបំបាក់ស្មារតីអ្នកស្នេហាជាតិ កុំឲ្យចូលរួមជាមួយរដ្ឋាភិបាល ក្នុងការការពារទឹកដីរបស់ខ្លួន ។ ប្រជាពលរដ្ឋខ្មែរ ក៏មិនចង់ដោះស្រាយជម្លោះរវាងប្រទេសជិតខាង ដោយការប្រើអាវុធដោយយុទ្ធវិធីឡើយ ប៉ុន្តែត្រូវដោះស្រាយដោយសន្តិវិធី ដើម្បីការរស់នៅដោយសុខខាន្តរវាងប្រទេសជិតខាងគ្នា ។ ប៉ុន្តែការដាក់ទាហានប្រចាំការឲ្យបានច្រើន ត្រង់កន្លែងណាដែលធ្លាប់មានជម្លោះគ្នាអំពីបញ្ហាព្រំដែនជាការចាំបាច់ ដើម្បីការពារទឹកដីរបស់ខ្លួន ។ ការដាក់ដើម្បីការពារទឹកដីពុំមែនដើម្បីធ្វើចម្បាំងទេ ព្រោះកាលណាមានទាហានច្រើន អ្នកដែលធ្លាប់រំកិលព្រំដែននឹងខ្លាចញញើត មិនអាចទន្រ្ទានយកទឹកដីបានដោយងាយៗឡើយ ។ ដូច្នេះទាហានមិនថាតែទាហានជើងគោកទេ ទោះបីទាហានជើងទឹកនិងជើងអាកាសក៏ដូចគ្នា គឺគេបង្កើតឡើងដើម្បីការពារទឹកដីរបស់ខ្លួន ។ ចុះទាហានខ្មែរ ដែលថាមានជាង១សែននាក់នោះ ទៅណាអស់ហើយ ពុំឮថាទៅប្រចាំការកន្លែងច្រកសំខាន់ៗ ដែលធ្លាប់មានរឿងវិវាទគ្នារវាងប្រទេសជិតខាងទាំងខាងកើតខាងលិច ។ ប្រជាពលរដ្ឋខ្មែរនៅតាមព្រំដែនមានដៃទទេ នៅពេលដែលប្រទេសជិតខាងចូលទន្រ្ទានយកទឹកដី ប្រជាពលរដ្ឋគ្មានអ្វីតទល់នឹងគេទេ មានតែដកថយដើម្បីរក្សាសន្តិសុខរបស់ខ្លួន បើមានទាហានប្រចាំការនៅទីនោះ អាចជាកម្លាំងរុញច្រានអ្នកឈ្លានពាននោះឲ្យត្រឡប់ទៅវិញ ។ នៅពេលថ្មីៗនេះ អនុប្រធាននៃព្រឹទ្ធសភានៃគណបក្សមួយដែលរួមរដ្ឋាភិបាល បានទៅធ្វើទស្សនកិច្ចជាមួយសហការីរបស់ខ្លួននៅព្រំដែនខ្មែរ-វៀតណាម ពេលទៅដល់គេពុំបានសាកសួរអំពីសេចក្តីទុក្ខវេទនារបស់ប្រជាពលរដ្ឋ ដែលដីរបស់គេត្រូវវៀតណាមទន្រ្ទានយកទេ គេគ្រាន់តែចែកអំណោយបន្តិចបន្តួចដូចជាក្រមាជាដើម ដើម្បីធ្វើប្រជាភិថុតិសំរាប់គណបក្សប៉ុណ្ណោះ ។ ប្រជាពលរដ្ឋនៅទីនោះពោលថា គេចង់ឲ្យអាជ្ញាធរខ្មែរជួយដោះស្រាយដីស្រែដែលវៀតណាមទន្រ្ទានយក ប៉ុន្តែប្រជាពលរដ្ឋនោះខកចិត្ត ដោយអនុប្រធានព្រឹទ្ធសភានោះ ពុំបាននិយាយមួយម៉ាត់អំពីបញ្ហាជាអទិភាពនេះឡើយ ។ នៅពេលអ្នកសារពត៌មានសាកសួរអំបីបញ្ហានេះ អនុប្រធាននោះឆ្លើយថា បញ្ហាទឹកដីនេះស្រេចតែក្រសួងមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាលដោះស្រាយចុះ ។ ដូច្នេះយើងឃើញច្បាស់ថា អនុប្រធានព្រឹទ្ធសភានោះ ពុំបានបំពេញមុខនាទីរបស់ខ្លួន ដោយយកពត៌មានពីសុខទុក្ខរបស់ប្រជាពលរដ្ឋឲ្យបានជាក់លាក់ ហើយធ្វើសំណើទៅរដ្ឋាភិបាលត្រង់កន្លែងណាដែលរដ្ឋាភិបាលពុំបានបំពេញ ស្របតាមសំណូមពររបស់ប្រជាពលរដ្ឋទេ ។ គណបក្សនីមួយៗពេលទៅសុំសន្លឹកឆ្នោតបីប្រជាពលរដ្ឋ តែងតែនិយាយយ៉ាងមុតមាំថា ប្តេជ្ញានិងសន្យាការពារបូរណភាពទឹកដីមិនឲ្យបាត់មួយចំអាមឡើយ លុះបានជាប់ជាតំណាងរាស្រ្ត ក៏គ្មានឃើញធ្វើដូចពាក្យសន្យានោះឡើយ មិនថាបាត់មួយចំអាមទេ ទោះបី

រាប់គីឡូម៉ែត្រក៏តំណាងរាស្ត្រទាំងនោះគ្មានរវល់ឡើយ ។ ប៉ុន្តែព្រឹទ្ធសភានៅអាណត្តិទី៣នេះទៀត កើតឡើងពីការចាត់តាំងរបស់គណបក្សនីមួយៗ ពុំមែនកើតឡើងពីការបោះឆ្នោតតាមរបបប្រជាធិបតេយ្យឡើយ ដូច្នេះហើយបានជាព្រឹទ្ធសភានោះ ពុំសូវរវីរវល់អំពីសុទ្ធទុក្ខរបស់ប្រជាពលរដ្ឋបែបនេះ ។ នៅពេលថ្មីៗនេះទៀត អាជ្ញាធរក្រសួងមហាផ្ទៃជនទៅជួបអាជ្ញាធរវៀតណាមនៅប្រទេសវៀតណាម ក៏មិនឮថា ភាគីទាំងពីលើកយកបញ្ហាព្រំដែន ដែលវិវាទគ្នានោះមកដោះស្រាយឡើយ ។ កាលពីមុន រាជរដ្ឋាភិបាលខ្មែរបានហាមឃាត់ការធ្វើបាតុកម្មនិងការធ្វើសន្និសិទរបស់ក្រុមចលនានិស្សិតជាច្រើនក្រុម និងគណៈកម្មាធិការការពារព្រំដែនខ្មែរដែលទៅពីប្រទេសបារាំង ដើម្បីការពារទឹកដីរបស់ខ្លួន ។ ការហាមឃាត់នេះ ចាត់ទុកជាការរំលោភសិទ្ធិក្នុងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋខ្មែរ ដែលបានចែងក្នុងរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្ន ក៏ដូចជាការរំលោភសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ។ តាមពិតការការពារទឹកដីពុំមែនស្ថិតនៅលើរដ្ឋាភិបាលទេ គឺប្រជាពលរដ្ឋទូទៅគ្រប់ឋានៈមានភារៈចូលរួមបញ្ចេញយោបល់ ហើយរដ្ឋាភិបាលគួរយកយោបល់នោះទៅពិចារណា ។ ការបំបាត់ស្មារតីស្នេហាជាតិ ស្នេហាទឹកដីរបស់ប្រជាពលរដ្ឋខ្មែរ មិនឲ្យបញ្ចេញយោបល់នេះ នាំឲ្យបកស្រាយថា ជារដ្ឋាភិបាលនៅក្រោមឥទ្ធិពលប្រទេសវៀតណាម ចង់រក្សាទុកសន្ធិសញ្ញាខុសច្បាប់ក្នុងអំឡុងឆ្នាំ១៩៨០, ជារដ្ឋាភិបាលផ្តាច់ការ ព្រោះពុំស្តាប់យោបល់ប្រជាពលរដ្ឋ, ជារដ្ឋាភិបាលពុំស្មោះត្រង់នឹងប្រជាពលរដ្ឋ ព្រោះចង់លាក់អាថ៌កំបាំងអ្វីមួយក្នុងបញ្ហាទឹកដីនេះ។ បើដំណោះស្រាយជាទ្វេភាគីខ្មែរ-វៀតណាមមិនអាចរកផ្លូវចេញរួចទេ គួររដ្ឋាភិបាលដាក់បញ្ហាព្រំដែននេះក្នុងតុលាការអន្តរជាតិ ដូចជាតុលាការក្រុងឡាអេ ទើបសង្ឃឹមថាយុត្តិធម៌ ព្រោះមតិទូទៅយល់ថា បើទោះបីរាជរដ្ឋាភិបាលខ្មែរដោះស្រាយបានជាមួយប្រទេសជិតខាងនេះក៏ដោយ ក៏គ្មានយុត្តិធម៌សំរាប់ប្រទេសកម្ពុជាឡើយ គឺខ្មែរនឹងបាត់បង់ទឹកដីរបស់ខ្លួន ហើយរដ្ឋាភិបាលខ្មែរត្រូវតែទទួលខុសត្រូវក្នុងការបាត់បង់ទឹកដីនេះ ។ មួយទៀត បើចង់ឲ្យប្រជាពលរដ្ឋទៅរស់នៅព្រំដែនឲ្យបានច្រើន ដែលទុកដូចជាធ្វើរបងការពារទឹកដីរបស់ខ្លួន រដ្ឋាភិបាលគួរចំណាយថវិកាសង់ផ្ទះ សង់មន្ទីរពេទ្យ សង់សាលារៀន ស្ថាបនាវត្ត បង្កើតផ្សារ និងធ្វើផ្លូវគមនាគមន៍ទាក់ទងពីទីក្រុងមកជនបទ បើធ្វើបានដូច្នេះប្រជាពលរដ្ឋនឹងទៅរស់នៅព្រំដែនបានច្រើន ទុកជារបងការពារទឹកដីរបស់ខ្លួន ។៚